ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សៀវភៅណែនាំស្តីពី
# បច្ចេកទេសចិញ្ចឹមកន្ធាយ







រៀបចំដោយ:
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
សហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល
ឧបត្ថម្ភការបោះពុម្ពដោយ: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២០២០



## មាតិកា ទំព័រ


I. **សេចក្តីផ្តើម** ........ ០១

II. **ស្ថានភាពទូទៅ** ........ ០៣

III. **លក្ខណៈជីវសាស្ត្រ** ........ ០៥

១. ចរិកស៊ីចំណី ........ ០៧

២. ការលូតលាស់ ........ ០៧

៣. ការបន្តពូជ ........ ០៨

IV. **បច្ចេកទេសចិញ្ចឹមកន្ធាយ** ........ ០៩

១. ប្រភពទឹកសម្រាប់ចិញ្ចឹមកន្ធាយ ........ ០៩

២. ការជ្រើសរើសកូនពូជដាក់ចិញ្ចឹម ........ ០៩

៣. ការរៀបចំស្រះចិញ្ចឹមកន្ធាយ ........ ១០

៤. ដង់ស៊ីតេកូនកន្ធាយដាក់ចិញ្ចឹម ........ ១២

៥. ចំណី និងការផ្តល់ចំណី ........ ១៣

៦. ការគ្រប់គ្រងស្រះ ........ ១៦

៧. ជំងឺ និងការបង្ការជំងឺ ........ ១៨

៨.ការប្រមូលផល ........ ២២






# បច្ចេកទេសចិញ្ចឹមកន្ធាយក្នុងស្រះ

## I. សេចក្តីផ្តើម

កន្ធាយ គឺជាប្រភេទសត្វឈាមត្រជាក់ ស្ថិតក្នុងអំបូរ Trionychidae ដែលបច្ចុប្បន្ននេះ រួមមានបីប្រភេទសំខាន់ បាន និងកំពុងចិញ្ចឹមក្នុងប្រទេសកម្ពុជាយើងគឺ កន្ធាយផ្កាមានឈ្មោះវិទ្យាសាស្ត្រ Tryonyx sinensis កន្ធាយបន្លា មានឈ្មោះវិទ្យាសាស្ត្រ Tryonyx steinachderi និងកន្ធាយស្មៅ មានឈ្មោះវិទ្យាសាស្ត្រ Tryonyx cartilagineus។

ការចិញ្ចឹមកន្ធាយ បាន និងកំពុងមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់បងប្អូនប្រជាកសិករ និងវារីវប្បករកម្ពុជាយើងនៅតាមបណ្តាខេត្តមួយចំនួននៅភាគខាងជើងប្រទេស ជាពិសេស នៅក្នុងខេត្តសៀមរាបដែលបានចាប់ដំណើរការចិញ្ចឹមចាប់តាំងពីឆ្នាំ២០០៨មកម្លេះ ក្រោមការដឹកនាំ ផ្តល់បច្ចេកទេសអនុវត្ត ធ្វើដោយផ្ទាល់ពីសំណាក់មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល ។ សកម្មភាពចិញ្ចឹមកន្ធាយតាមបែបជាលក្ខណៈគ្រួសារនេះ បន្ទាប់ពីបានទទួលជោគជ័យលទ្ធផលល្អជាបណ្តើរៗកន្លងមក ពោលគឺចាប់ឆ្នាំ២០០៨ កន្លងមកនេះ ក៏បានធ្វើឱ្យកសិករផ្សេងៗទៀតនៅក្នុងតំបន់ មូលដ្ឋាន ខេត្តសៀមរាប ជាពិសេស វារីវប្បករវ័យក្មេងៗជំនាន់ក្រោយជាច្រើនបានចាប់អារម្មណ៍ចិញ្ចឹមបន្តមកដល់ឆ្នាំ២០២០ នាពេលបច្ចុប្បន្ននេះ។ ការចិញ្ចឹមកន្ធាយ នាពេលបច្ចុប្បន្ននេះ បានកំពុងក្លាយជាមុខរបរថ្មីមួយដ៏សំខាន់ តាមបែបពាណិជ្ជកម្ម របស់វារីវប្បករវ័យក្មេងមួយចំនួននៅខេត្តសៀមរាបក្នុងប្រទេសកម្ពុជាយើង បើប្រៀបធៀបទៅនឹងមុខរបរចិញ្ចឹមត្រី ចិញ្ចឹមកង្កែប ឬមុខរបរកសិកម្មផ្សេងទៀត។ របរចិញ្ចឹមកន្ធាយនេះ ត្រូវបានគេអះអាងថា មានតម្រូវការលើទីផ្សារខ្ពស់ ដោយសារតែវាជាម្ហូបអាហារ ពេញនិយមនៅតាមបណ្តាភោជនីយដ្ឋាន ឬអាហារដ្ឋានជាច្រើននៅក្នុងខេត្តសៀមរាប ក៏ដូចជានៅតាមបណ្តាខេត្តផ្សេងៗទៀតដែលស្ថិតក្នុងតំបន់ទេសចរណ៍។




*កសិករ ប៉ៃ សំអូន នៅភូមិប្រាសាទ ឃុំសំរោងយារ ស្រុកពួក ខេត្តសៀមរាប កំពុងជោគជ័យលើមុខរបរចិញ្ចឹមកន្ធាយ*

ដោយមើលឃើញថា កន្ធាយ ជាវារិសត្វមួយប្រភេទ មានសក្តានុពលខ្លាំងនៅក្នុងវិស័យវារីវប្បកម្ម បន្ទាប់ពីបង្កង ហើយវាក៏មានតម្លៃសេដ្ឋកិច្ចខ្ពស់ផងដែរនៅលើទីផ្សារ ទាំងនៅក្នុងស្រុក តាមតំបន់មូលដ្ឋាននានានៃប្រទេសកម្ពុជា និងសម្រាប់ការនាំចេញទៅក្រៅប្រទេសនាពេលអនាគត នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយ នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល ក្រោមការចង្អុលបង្ហាញពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំរៀបចំចងក្រងកូនសៀវភៅណែនាំស្តីពីបច្ចេកទេសចិញ្ចឹមកន្ធាយនេះឡើង ក្នុងគោលបំណង លើកទឹកចិត្តឱ្យមានការចិញ្ចឹមកន្ធាយក្នុងស្រុក ឱ្យបានកាន់តែច្រើនបន្ថែមទៀតខណៈពេលដែលបច្ចុប្បន្ននេះការចិញ្ចឹមនៅមានចំនួនតិចតួចនៅឡើយ ក៏ដូចជាការផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹម នៅមានកម្រិត។

ការចូលរួមរបស់ផ្នែកឯកជន លើការវិនិយោគវិស័យជលផល ពិសេសផ្នែកវារីវប្បកម្ម គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការចូលរួមចំណែកជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជារាជរដ្ឋាភិបាលដើម្បីបង្កើនបរិមាណផ្គត់ផ្គង់ក្នុងស្រុក និងធានាបានទាំងបរិមាណ គុណភាព និងតម្លៃ ឆ្លើយតបតាមសេចក្តីត្រូវការទីផ្សារដែលកំពុងមានតម្រូវការកាន់តែខ្ពស់ពីមួយថ្ងៃទៅមួយថ្ងៃ។

ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានជំរុញឱ្យផ្នែក